# មេរៀន
# ស្តីពី
# គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី..... ខែឧសភា ឆ្នាំ២០១៥ នៅសាលាភូមិន្ទរដ្ឋបាល

I. មូលដ្ឋានគតិយុត្ត

- ព្រះរាជក្រឹត្យលេខ ២៧ រវ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៦៣ ស្តីពីលំដាប់ថ្នាក់នៃគ្រឿងឥស្សរិយយស
- ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- អនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ១៩៩៤ ស្តីពីការបង្កើតមេដាយស្ថាបនាជាតិនិងបណ្ណស្ថាបនាជាតិដើម្បីជូនដល់សប្បុរស...
- អនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការបង្កើតគណៈកម្មការមួយមានឈ្មោះថា គណៈកម្មការពិនិត្យលក្ខណៈសម្បត្តិវរជន មន្រ្តីរាជការដែលត្រូវផ្តល់គ្រឿង ឥស្សរិយយស
- អនុក្រឹត្យលេខ ៥៦៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលមាត្រា២នៃអនុក្រឹត្យលេខ៦៦ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការបង្កើតគណៈកម្មការមួយមានឈ្មោះថា គណៈកម្មការពិនិត្យលក្ខណៈសម្បត្តិវរជន មន្រ្តីរាជការដែលត្រូវផ្តល់គ្រឿងឥស្សរិយយស
- សេចក្តីសម្រេចលេខ ៤៥ សសរ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតគណៈកម្មការពិនិត្យលក្ខណៈសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស
- សេចក្តីសម្រេចលេខ ០១ សសរ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០០៣ ស្តីពីការបង្កើតក្រុមការងារពិនិត្យ ផ្តល់មតិជូនគ្រឿងឥស្សរិយយស និងការអនុញ្ញាតឱ្យស្នាក់នៅដល់ធុរជនបរទេស
- សេចក្តីសម្រេចលេខ ៦១ សសរ ចុះថ្ងៃទី២០ ខែមិនា ឆ្នាំ២០១៤ ស្តីពីការតែងតាំងសមាសភាពគណៈកម្មការពិនិត្យលក្ខណៈសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស
- សារាចរណែនាំលេខ ០៧ សរណន ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការរៀបចំបែបបទស្នើសុំគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- សារាចរណែនាំលេខ ០១ សរណន ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០០១ ស្តីពីការរៀបចំបែបបទស្នើសុំគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- សារាចរណែនាំលេខ ១០ សរណន ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០០៤ ស្តីពីការពាក់គ្រឿងឥស្សរិយយស

II. ខ្លឹមសារនៃមេរៀន

ក/ ប្រភេទលិខិតបទដ្ឋានគតិយុត្តសម្រាប់ផ្ដល់គ្រឿងឥស្សរិយយស

1. ប្រទានតាមព្រះរាជក្រឹត្យ រួមមាន ប្រភេទមាតុប្រទេស ប្រភេទរាជបល្ល័ង្ក និងប្រភេទការពារជាតិ ព្រមទាំងថ្នាក់មហាសេរីវឌ្ឍន៍ និង ថ្នាក់មហាសេនានៃមេដាយសហមេត្រី មេដាយសុវត្ថារា និងមេដាយមុនីសារាភ័ណ្ឌ។

2. ផ្ដល់ជូនតាមអនុក្រឹត្យ ប្រភេទចម្រុះ រួមមាន
   - មេដាយសហមេត្រីថ្នាក់ធិបឌិន ថ្នាក់សេនា ថ្នាក់អស្សប្ញទ្ធិ
   - មេដាយសុវត្ថារាថ្នាក់ធិបឌិន ថ្នាក់សេនា ថ្នាក់អស្សប្ញទ្ធិ
   - មេដាយមុនីសារាភ័ណ្ឌថ្នាក់ធិបឌិន ថ្នាក់សេនា ថ្នាក់អស្សប្ញទ្ធិ
   - មេដាយការងារថ្នាក់មាស ថ្នាក់ប្រាក់ ថ្នាក់សំរិទ្ធ
   - មេដាយស្ថាបនាជាតិថ្នាក់មាស ថ្នាក់ប្រាក់ ថ្នាក់សំរិទ្ធ
   - មេដាយខេមរាកីឡាប្ញទ្ធិថ្នាក់មាស ថ្នាក់ប្រាក់ ថ្នាក់សំរិទ្ធ
   - មេដាយស្ត្រីវឌ្ឍនាថ្នាក់មាស ថ្នាក់ប្រាក់ ថ្នាក់សំរិទ្ធ

II. ខ្លឹមសារនៃមេរៀន

ខ/ គោលការណ៍សម្រាប់ផ្តល់គ្រឿងឥស្សរិយយស

ប្រភេទមាតុប្រទេស រួមមាន៖

១. មេដាយជាតូបការៈ

២. មេដាយព្រះរាជាណាចក្រកម្ពុជាមាន៥ថ្នាក់មហាសេរីវឌ្ឍន៍ មហាសេនា ធិបឌិន្ទ សេនា អស្សឫទ្ធិ

៣. មេដាយឯករាជជាតិ

- គ្រឿងឥស្សរិយយសប្រភេទនេះ សម្រាប់បំពាក់ជូនវរជនដែលមានគុណូបការៈដ៏ឧត្តុង្គឧត្តម ក្នុងការបម្រើមាតុប្រទេស ដើម្បីបុព្វហេតុឯករាជ្យ សាមគ្គីភាព ប្រជាធិបតេយ្យ និង សន្តិភាពជាតិ តាមរយៈព្រះរាជក្រឹត្យ ក្រោយពីការសម្រេចរបស់គណៈរដ្ឋមន្ត្រី ហើយត្រូវប្រទានដោយព្រះមហាក្សត្រ ឬដោយព្រះរាជតំណាង។



II. ខ្លឹមសារនៃមេរៀន

ប្រភេទរាជបល្ល័ងរួមមាន៖

១. មេដាយរាជសម្បត្តិ

២. មេដាយរដ្ឋកាល មាន ៣ថ្នាក់ : មាស ប្រាក់ សំរិទ្ធ

៣. មេដាយអនុស្សរា

- គ្រឿងឥស្សរិយយសប្រភេទនេះ សម្រាប់បំពាក់ជូនវរជនដែលមានគុណបំណាច់ចំពោះព្រះរាជបល្ល័ង្ក ចំពោះព្រះមហាក្សត្រផ្ទាល់ ចំពោះព្រះរាជវង្សានវង្សានុវង្សព្រះមហាក្សត្រ ឬ ជាអនុស្សាវរីយ៍របស់ព្រះមហាក្សត្រ។ ការផ្តល់ និង បំពាក់គ្រឿងឥស្សរិយយស់ទាំងនេះ ត្រូវសំរេចដោយព្រះរាជតំរិះផ្ទាល់របស់ព្រះមហាក្សត្រ តាមរយៈក្រឹត្យបរមរាជវាំង។







II. ខ្លឹមសារនៃមេរៀន

ប្រភេទការពារជាតិ

១. មេដាយសេនាជ័យសិទ្ធ

២. មេដាយការពារជាតិ មាន ៣ថ្នាក់ : មាស ប្រាក់ សំរិទ្ធ

គ្រឿងឥស្សរិយយសទាំងនេះ សម្រាប់បំពាក់ជូនដល់ពលទាហាន នាយកទាហាននៃកងកំលាំងប្រដាប់អាវុធឬនគរបាលដែលមានស្នាដៃឆ្នើមពិសេសក្នុងសង្គ្រាមឬកិច្ចការពារព្រំដែននិងការពារសន្តិសុខជូនជាតិមាតុភូមិ តាមរយៈព្រះរាជក្រឹត្យក្រោយពីការសំរេចរបស់គណៈរដ្ឋមន្ត្រី ហើយត្រូវប្រទានដោយព្រះមហាក្សត្រឬព្រះរាជតំណាង។




មេដាយជ័យសិទ្ធ

Sena Jayaseddh Medal




មេដាយមាសការពារជាតិ National Defense Medal Gold

មេដាយប្រាក់ការពារជាតិ National Defense Medal Silver

មេដាយសំរិទ្ធការពារជាតិ National Defense Medal Bronze

II. ខ្លឹមសារនៃមេរៀន

ប្រភេទចំរុះ

១. មេដាយសហមេត្រីមាន៣ថ្នាក់ : ធិបឌិន្ទ សេនា អស្សឫទ្ធិ សម្រាប់បំពាក់ជូនអង្គទូតឬតំណាងប្រទេសជាមិត្តដែលបានបំពេញការងារដើម្បីជាប្រយោជន៍ដល់ចំណងមិត្តភាពប្រទេសទាំងពីរ ផ្តល់ជូនដោយអនុក្រឹត្យ។ តែការអនុវត្តជាក់ស្តែងមេដាយសហមេត្រីបន្ថែម២ថ្នាក់គឺថ្នាក់មហាសេរីវឌ្ឍន៍និងថ្នាក់មហាសេនា ប្រទានតាមព្រះរាជក្រឹត្យ។









II. ខ្លឹមសារនៃមេរៀន

ប្រភេទចំរុះ

២. មេដាយសុវត្ថារាមាន៣ថ្នាក់ : ធិបឌិន្ទ សេនា អស្សប្ញទ្ធិសំរាប់បំពាក់ជូនបុគ្គលដែលមានស្នាដៃ និង គុណបំណាងខ្ពស់ក្នុងវិស័យកសិកម្ម និង សេដ្ឋកិច្ច។ តែការអនុវត្តជាក់ស្ដែងមេដាយសុវត្ថារាបន្ថែម២ថ្នាក់គឺ ថ្នាក់មហាសេរីវឌ្ឍន៍និងថ្នាក់មហាសេនា ប្រទានតាមព្រះរាជក្រឹត្យ។









II. ខ្លឹមសារនៃមេរៀន

ប្រភេទចំរុះ

៣. មេដាយមុនីសារាភ័ណ្ឌមាន៣ថ្នាក់ : ធិបឌិន្ទ សេនា អស្សប្ញទ្ធិ សំរាប់បំពាក់ជូនបុគ្គលដែលមានស្នាដៃ និង គុណបំណាច់ខ្ពស់ ក្នុងវិស័យសិក្សាធិការ អក្សរសាស្ត្រ វិទ្យាសាស្ត្រ វិចិត្រសិល្បៈ សង្គមកិច្ច ឬ វិស័យផ្សេងៗទៀត ផ្តល់ជូនដោយអនុក្រឹត្យ។ តែការអនុវត្តដាក់ស្តែងមេដាយមុនីសារាភ័ណ្ឌបន្ថែម២ថ្នាក់គឺ ថ្នាក់មហាសេរីវឌ្ឍន៍និងថ្នាក់មហាសេនា ប្រទានតាមព្រះរាជក្រឹត្យ។









II. ខ្លឹមសារនៃមេរៀន

ប្រភេទចំរុះ

៤. មេដាយការងារមាន៣ថ្នាក់ : មាស ប្រាក់ សំរិទ្ធ សម្រាប់បំពាក់ជូនបុគ្គលដែលមានថ្វីដៃក្នុងការងារផ្នែករដ្ឋបាល ឬ ក្នុងវិស័យឯកជន។ មេដាយខាងលើនេះ សម្រេចតាមរយៈអនុក្រឹត្យនិងបំពាក់ដោយនាយករដ្ឋមន្ត្រីឬតំណាង។



មេដាយមាសការងារ
Medal Of Labor Gold

មេដាយប្រាក់ការងារ
Medal Of Labor Silver

មេដាយសំរិទ្ធការងារ
Medal Of Labor Bronze

II. ខ្លឹមសារនៃមេរៀន

ប្រភេទចំរុះ

៥. មេដាយស្ថាបនាជាតិមាន៣ថ្នាក់ : មាស ប្រាក់ សំរិទ្ធ សម្រាប់បំពាក់ជូនសប្បុរសជន ដែលបានបរិច្ចាគទ្រព្យសម្បត្តិផ្ទាល់ខ្លួន ជួយកសាងជាតិ ឬស្ថាបនា សមិទ្ធិជាប្រយោជន៍សាធារណៈ។ មេដាយខាងលើនេះ សម្រេចតាមរយៈអនុក្រឹត្យនិងបំពាក់ដោយនាយករដ្ឋមន្ត្រីឬតំណាង។



II. ខ្លឹមសារនៃមេរៀន

ប្រភេទចំរុះ

៦. មេដាយខេមរាកីឡាឫទ្ធិមាន៣ថ្នាក់ : មាស ប្រាក់ សំរិទ្ធ សម្រាប់បំពាក់ជូនកីឡាករដែលមានស្នាដៃឆ្នើមក្នុងវិស័យកីឡាជាតិឬអន្តរជាតិដែលបាននាំមកនូវកិត្តិយសដល់ប្រទេសជាតិ។ មេដាយខាងលើនេះ សម្រេចតាមរយៈអនុក្រឹត្យនិងបំពាក់ដោយនាយករដ្ឋមន្ត្រីឬតំណាង។



II. ខ្លឹមសារនៃមេរៀន

ប្រភេទចំរុះ

៧. មេដាយស្ត្រីវឌ្ឍនាមាន៣ថ្នាក់ : មាស ប្រាក់ សំរិទ្ធ សម្រាប់បំពាក់ជូនស្ត្រីឬបុរសដែលមានគុណូបការៈខ្ពង់ខ្ពស់ក្នុងការលើកតំកើង បុព្វហេតុស្ត្រី។ មេដាយខាងលើនេះ សម្រេចតាមរយៈអនុក្រឹត្យនិងបំពាក់ដោយនាយករដ្ឋមន្ត្រីឬតំណាង។



II. ខ្លឹមសារនៃមេរៀន

របៀបពាក់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា មានបីប្រភេទគឺពាក់ដូចពាក់ខ្សែករ ពាក់ឈាងពីស្មាស្តាំមកឆ្វេង និងពាក់ព្យួរពីលើហោប៉ៅអាវដែលមានគម្របខាងឆ្វេង។

## របៀបពាក់គ្រឿងឥស្សរិយយស បុរស និងស្ត្រីក្នុងឱកាសពិធីផ្សេងៗ(ដកស្រង់ឯកសាររូបភាពបរទេស)



## II. ខ្លឹមសារនៃមេរៀន

ទម្រង់ប្រភេទនៃប្រកាសនិយប័ត្រគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជាមានដូចខាងក្រោម៖

១- ទម្រង់ប្រកាសនិយប័ត្រគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជាថ្នាក់មហាសេរីវឌ្ឍន៍


ព្រះរាជាណាចក្រកម្ពុជា

ប្រកាសនីយប័ត្រ គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍

## II. ខ្លឹមសារនៃមេរៀន

ទម្រង់ប្រភេទនៃប្រកាសនិយប័ត្រគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជាមានដូចខាងក្រោម៖

២- ទម្រង់ប្រកាសនិយប័ត្រគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជាថ្នាក់មហាសេនា ធិបឌិន្ទ



## II. ខ្លឹមសារនៃមេរៀន

ទម្រង់ប្រភេទនៃប្រកាសនិយប័ត្រគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជាមានដូចខាងក្រោម៖

៣- ទម្រង់ប្រកាសនិយប័ត្រគ្រឿងឥស្សរិយយសសហមេត្រីថ្នាក់មហាសេរីវឌ្ឍន៍និងមហាសេនា






II. ខ្លឹមសារនៃមេរៀន

ទម្រង់ប្រភេទនៃប្រកាសនិយប័ត្រគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជាមានដូចខាងក្រោម៖

៤- ទម្រង់ប្រកាសនិយប័ត្រគ្រឿងឥស្សរិយយសសុវត្ថារាថ្នាក់មហាសេរីវឌ្ឍន៍និងមហាសេនា






## II. ខ្លឹមសារនៃមេរៀន

ទម្រង់ប្រភេទនៃប្រកាសនិយប័ត្រគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជាមានដូចខាងក្រោម៖

៥- ទម្រង់ប្រកាសនិយប័ត្រគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌថ្នាក់មហាសេរីវឌ្ឍន៍និងមហាសេនា






II. ខ្លឹមសារនៃមេរៀន

ទម្រង់ប្រភេទនៃប្រកាសនិយប័ត្រគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជាមានដូចខាងក្រោមៈ

៦- ទម្រង់ប្រកាសនិយប័ត្រគ្រឿងឥស្សរិយយសការពារជាតិនិងសហមេត្រី






II. ខ្លឹមសារនៃមេរៀន

ទម្រង់ប្រភេទនៃប្រកាសនិយប័ត្រគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជាមានដូចខាងក្រោម៖

៧- ទម្រង់ប្រកាសនិយប័ត្រគ្រឿងឥស្សរិយយសសុវត្ថារានិងមុនីសារាភ័ណ្ឌ






II. ខ្លឹមសារនៃមេរៀន

ទម្រង់ប្រភេទនៃប្រកាសនិយប័ត្រគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជាមានដូចខាងក្រោម៖

៨- ទម្រង់ប្រកាសនិយប័ត្រគ្រឿងឥស្សរិយយសការងារនិងមេដាយមាសស្ថាបនាជាតិ






# សូមអរគុណ !

ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១

ចុះថ្ងៃទី ០៥/១០/៩៥

# ប្រភេទឋានន្តរស័ក្តិនៃគ្រឿងឥស្សរិយយស

## ប្រភេទមាតុប្រទេស (ក)

តាមរយៈព្រះរាជក្រឹត្យ ✓ ក្រោយពីការសំរេចរបស់គណៈរដ្ឋមន្ត្រី

- សំរាប់បំពាក់ជូនចំពោះវរជនដែលមានគុណដ៏ឧត្តុងឧត្តមការបំរើមាតុប្រទេស

- (១) មេដាយជាតូបការៈ
- (២) មេដាយព្រះរាជាណាចក្រកម្ពុជា (៥ថ្នាក់)
  - -មហាសេរីវឌ្ឍន៍ -មហាសេនា -ធិបឌិន្ទ -សេនា -អស្សឫទ្ធិ
- (៣) មេដាយឯករាជ្យជាតិ

## ប្រភេទព្រះរាជបល្ល័ង្ក (ខ)

-សំរេចដោយព្រះរាជតំរិះផ្ទាល់របស់ព្រះមហាក្សត្រ

សំរាប់បំពាក់ជូនវរជនដែលមានគុណបំណាច់ចំពោះព្រះរាជបល្ល័ង្ក
-ចំពោះព្រះមហាក្សត្រ
-ចំពោះព្រះរាជវង្សានុវង្ស

- (១) មេដាយរាជសម្បត្តិ
- (២) មេដាយរជ្ជការ
  - -មាស -ប្រាក់ -សំរិទ្ធ
- (៣) មេដាយអនុរាស្សា

## ប្រភេទការពារជាតិ (គ)

-សំរាប់បំពាក់ជូននាយទាហាន ឬនគរបាលដែលមានស្នាដៃឆ្នើមពិសេសក្នុងសង្គ្រាមឬកិច្ចការព្រំដែន

- (១) មេដាយសេនាជ័យសិទ្ធិ
- (២) មេដាយការពារជាតិ
  - -មាស -ប្រាក់ -សំរិទ្ធ

## ប្រភេទចំរុះ (ឃ)

-សំរេចតាមរយៈអនុក្រឹត្យ ✓

- (១) មេដាយសហមេត្រី — -សំរាប់បំពាក់ជូនអង្គទូត
  - -ធបឌិន -សេនា -អស្សឫទ្ធិ
- (២) មេដាយសុវត្ថារា — -បំពាក់ជូនបុគ្គលមានស្នាដៃក្នុងវិស័យកសិកម្ម និងសេដ្ឋកិច្ច
  - -ធបឌិន -សេនា -អស្សឫទ្ធិ
- (៣) មេដាយមុនីសារាភ័ណ្ឌ — -បំពាក់ជូនបុគ្គលមានស្នាដៃសិក្សាធិការ និងសង្គមកិច្ច
  - -ធបឌិន -សេនា -អស្សឫទ្ធិ
- (៤) មេដ[illegible]
  - -មាស -ប្រាក់ -សំរិទ្ធ
- (៥) មេដាយស្ថាបនាជាតិ — -បំពាក់ជូនសប្បុរសជនដែលបានបរិច្ចាគទ្រព្យសម្បត្តិផ្ទាល់ខ្លួនជួយជាតិ
  - -មាស -ប្រាក់ -សំរិទ្ធ

- មេដាយខេមរកីឡាឫទ្ធី →
  - -មាស
  - -ប្រាក់ (បំពាក់ជូនកឡាករដែលមានស្នាដៃឆ្នើម)
  - -សំរិទ្ធ

-មេដាយស្រីវឌ្ឍនា →
  - -មាស
  - -ប្រាក់ (បំពាក់ជូនស្ត្រី ឬបុរសដែលគុណូបការៈខ្ពង់ខ្ពស់លើកតំកើងបុព្វហេតុស្ត្រី)
  - -សំរិទ្ធ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១០ សរណន

លេខាធិការដ្ឋានមុខងារសាធារណៈ
រដ្ឋបាល

# សារាចរណែនាំ
# ស្តីពីការពាក់គ្រឿងឥស្សរិយយស

កន្លងមករាជរដ្ឋាភិបាល បានពិនិត្យឃើញថា មានមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ សប្បុរសជន ក្នុងប្រទេស និង ក្រៅប្រទេស ព្រមទាំងជនបរទេសជាច្រើន បានចូលរួមក្នុងកិច្ចការពារជាតិមាតុភូមិ និង អភិវឌ្ឍន៍ប្រទេសជាតិឡើងវិញ ហើយត្រូវបានព្រះមហាក្សត្រ និង រាជរដ្ឋាភិបាល បានលើកទឹកចិត្តផ្តល់គ្រឿងឥស្សរិយយស ទៅតាមទំហំស្នាដៃដែលសំរេចបាន និង មានរៀបចំពិធីបំពាក់ជាបន្តបន្ទាប់ ។

ដើម្បីអោយមានការឯកភាពគ្នា ក្នុងការពាក់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាល សូមធ្វើការណែនាំដល់គ្រប់ក្រសួង ស្ថាប័ន ខេត្ត ក្រុង អំពីរបៀបពាក់គ្រឿងឥស្សរិយយស ដូចខាងក្រោមនេះ:-

១-រាល់គ្រឿងឥស្សរិយយសគ្រប់ប្រភេទ លុះត្រាតែមានចេញព្រះរាជក្រឹត្យ អនុក្រឹត្យ ហើយទើបមានសិទ្ធិយកទៅបំពាក់ជូនដល់អ្នកមានស្នាដៃទាំងនោះបាន ។ ក្នុងការបំពាក់នេះ ត្រូវរៀបចំពិធីអោយបានត្រឹមត្រូវ មានសភាពអធិកអធម ដូចជាក្នុងពិធីសម្ពោធ មិទ្ទីញ សិក្ខាសាលា ជាដើម ។ ក្នុងករណីពិសេសបន្ទាន់ និង ចាំបាច់ និងមានការអនុញ្ញាតពីរាជរដ្ឋាភិបាល អាចរៀបចំពិធីបំពាក់ជាមុន នូវគ្រឿងឥស្សរិយយស ដែលចេញដោយអនុក្រឹត្យ រួចនឹងធ្វើសំណុំបែបបទជាក្រោយ ។

២-គ្រឿងឥស្សរិយយសប្រភេទណាក៏ដោយ ក្រោយពីព្រះមហាក្សត្រ ចេញព្រះរាជក្រឹត្យ និង រាជរដ្ឋាភិបាល ចេញអនុក្រឹត្យរួចហើយ អ្នកដែលមានសិទ្ធិបំពាក់នោះ គឺជាមន្ត្រីជាន់ខ្ពស់ ដែលព្រះមហាក្សត្រ ឬ រាជរដ្ឋាភិបាល ទ្រង់ព្រះរាជានុញ្ញាត និង អនុញ្ញាតអោយទៅជាតំណាង ទើបមានសិទ្ធិបំពាក់បាន ។

៣-របៀបបំពាក់គ្រឿងឥស្សរិយយស ត្រូវពាក់ទៅតាមឋានានុក្រម ពីធំទៅតូច និង ពីស្តាំទៅឆ្វេង អ្នកដែលពាក់ ដូចខាងក្រោមនេះ :-

-មេដាយជាតូបការ គឺជាមេដាយខ្ពស់បំផុតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងការបំពាក់មេដាយ នេះ គឺពាក់របៀបដូចជាពាក់ខ្សែកដែលមានបន្តោង ។

-មេដាយដែលមានថ្នាក់ មហាសេរីវឌ្ឍន៍ ថ្នាក់ មហាសេនា ត្រូវពាក់ជាមួយសំពត់រុយបង់ពីលើស្មាខាងស្តាំ បញ្ឆៀងមកចង្កេះខាងឆ្វេង ។ ប៉ុន្តែក្នុងករណីមិនពាក់ជាមួយសំពត់រុយបង់ទេ គឺត្រូវពាក់នៅដើមទ្រូង ក្រោមហោប៉ៅអាវខាងឆ្វេង ។

-មេដាយគ្រប់ប្រភេទ ដែលមានថ្នាក់ធិបឌិន្ទ ត្រូវពាក់ព្យួរនឹងក ដែលចងភ្ជាប់ជាមួយសំពត់រុយបង់ ហើយតួមេដាយត្រូវអោយធ្លាក់មកចំកណ្តាលដើមទ្រូង ។

-មេដាយដែលមានតែមួយថ្នាក់ និង មេដាយថ្នាក់ សេនា អស្សឫទ្ធិ ហើយនិង មាស ប្រាក់ សំរិទ្ធ ត្រូវពាក់នៅលើគំរបហោប៉ៅអាវខាងឆ្វេង ស្មើនឹងឡេវអាវទី២ ដោយតម្រៀបគ្នាពីស្តាំទៅឆ្វេង ពីថ្នាក់ខ្ពស់ ទៅថ្នាក់ទាប ។ ក្នុងករណីបានទទួលមេដាយច្រើនប្រភេទ ត្រូវពាក់មេដាយដែលចេញដោយព្រះរាជក្រឹត្យលើ ហើយថ្នាក់អនុក្រឹត្យ នៅក្រោមបន្ទាប់ និង តាមលំដាប់ថ្នាក់មេដាយ ។

-រាល់សញ្ញាសំគាល់សក្តិ សញ្ញាសំគាល់ក្រសួង ស្ថាប័ន អង្គភាពនិមួយៗ ត្រូវពាក់នៅលើគំរបហោប៉ៅអាវខាងស្តាំ មិនគប្បីពាក់នៅដើមទ្រូងខាងឆ្វេងទេ ព្រោះខាងឆ្វេងទុកសំរាប់បំពាក់គ្រឿងឥស្សរិយយស ប៉ុណ្ណោះ ។

៤-តួមេដាយគ្រប់ប្រភេទ ពាក់បានតែក្នុងពិធីបុណ្យជាតិ និង បុណ្យប្រពៃណីជាតិធំៗ ដូចជាបុណ្យឯករាជ្យជាតិ បុណ្យអុំទូក ជាដើម ពាក់តែតួមេដាយ មិនពាក់បារ៉ែតទេ គឺពាក់ជាមួយឯកសណ្ឋានធំ ក្រៅពីនេះដូចជាថ្ងៃធ្វើការងារ ឬ ក្នុងពិធីប្រជុំធំៗ អាចពាក់បានតែនៅលើឯកសណ្ឋានការងារ ហើយត្រូវពាក់តែបារ៉ែតទេ ដោយគ្មានតួមេដាយ ។

រាជរដ្ឋាភិបាល សង្ឃឹមជឿជាក់ថា គ្រប់ក្រសួង ស្ថាប័ន គ្រប់ជាន់ថ្នាក់ នឹងចាត់ចែងអនុវត្តតាមខ្លឹមសារនៃសារាចរណែនាំនេះ ប្រកបដោយស្មារតីយកចិត្តទុកដាក់ សំដៅរក្សាអោយបាននូវតម្លៃនៃគ្រឿងឥស្សរិយយសរបស់ជាតិ ។

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យសម្តេច និង ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- -គ្រប់ក្រសួង ស្ថាប័ន រដ្ឋលេខាធិការដ្ឋាន
- -គ្រប់ខេត្ត ក្រុង
- -រាជកិច្ច
- -កាលប្បវត្តិ-ឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០១ សរណន.

# សារាចរណែនាំ

## ស្តីពីការរៀបចំ បែបបទស្នើគ្រឿង ឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា

********

ដើម្បីជាការលើកទឹកចិត្ត ព្រមទាំងចារឹកទុកនូវគុណបំណាច់ និងស្នាដៃដ៏ខ្ពង់ខ្ពស់ក្នុងការ ការពារ និង កសាង ប្រទេស រាជរដ្ឋាភិបាលធ្លាប់បានបំពាក់នូវគ្រឿងឥស្សរិយយសរបស់ជាតិគ្រប់ប្រភេទ ជូនចំពោះជនរួមជាតិ និង មិត្តភក្តិបរទេស ស្របទៅតាមទំហំស្នាដៃ និង គុណបំណាច់របស់បុគ្គលម្នាក់ៗ ឬ សមូហភាពនីមួយៗ ។ គោល-នយោបាយលើកទឹក ចិត្ត និងផ្តល់កិត្តិយសខាងលើនេះ ត្រូវបានទទួលការអបអរសាទរពីគ្រប់មជ្ឈដ្ឋាន ។ ទន្ទឹមនឹងលទ្ធផលដ៏ល្អខាងលើនេះ រាជរដ្ឋាភិបាលក៏បានសង្កេតឃើញថា នៅមានការខ្វះចន្លោះមួយចំនួន ដែលចាំបាច់ត្រូវមានការកែលំអឡើងវិញ ដើម្បី អោយការផ្តល់គ្រឿងឥស្សរិយយសរបស់ជាតិមានភាពត្រឹមត្រូវ យុត្តិធម៌ និងរក្សាបាននូវមោទនភាពដ៏ខ្ពង់ខ្ពស់របស់ជាតិយើង ស្របតាមព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា និង អនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០០ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស រាជរដ្ឋាភិបាលសូមធ្វើការណែនាំដល់ គ្រប់ក្រសួង ស្ថាប័ន អំពីបែបបទនៃការស្នើសុំគ្រឿងឥស្សរិយយសគ្រប់ប្រភេទ ដូចមានខ្លឹមសារខាងក្រោមនេះ ÷

១- ដើម្បីរក្សាតម្លៃគ្រឿងឥស្សរិយយសរបស់ជាតិ និងដើម្បីអោយរបៀបរបបការងាររដ្ឋបាលដំណើរការបានល្អ រាល់សំណើសុំគ្រឿងឥស្សរិយយសទាំងអស់ ចាំបាច់ត្រូវឆ្លងតាមគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវស្នើគ្រឿងឥស្សរិយយសរបស់រាជរដ្ឋាភិបាល ដូចមានចែងក្នុងអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី១៥ ខែ កញ្ញា ឆ្នាំ ២០០០ ក្រោយពីសារាចរណែនាំនេះចូលជាធរមាន ។

២- គ្រប់ក្រសួងស្ថាប័នមានសមត្ថកិច្ច ត្រូវបង្កើតអោយមាន " គណៈកម្មការពិនិត្យលក្ខណសម្បត្តិបេក្ខ-ជន ដែលត្រូវស្នើសុំគ្រឿងឥស្សរិយយស " មួយដែលមានថ្នាក់ដឹកនាំក្រសួងស្ថាប័នផ្ទាល់ ជាប្រធានគណៈកម្មការ

និង ថ្នាក់ដឹកនាំអង្គភាពសំខាន់ៗ ក្រោមឱវាទក្រសួងស្ថាប័ន ជាសមាជិក ។ គណៈកម្មការនេះមានភារកិច្ចពិនិត្យលក្ខណសម្បត្តិវរជន មន្ត្រីរាជការក្រោមឱវាទ សំរាប់ជ្រើសរើសជាបេក្ខជនស្នើសុំគ្រឿងឥស្សរិយយសទៅតាមប្រភេទ និងវិស័យការងារ ដូចមានចែងក្នុងព្រះរាជក្រឹត្យ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា ដែលមានជូនភ្ជាប់មកជាមួយនេះស្រាប់ ក្រោយពេលគណៈកម្មការពិនិត្យជ្រើសរើស និងមានការឯកភាពពីប្រធានស្ថាប័នរួចហើយ ក្រសួងស្ថាប័នត្រូវធ្វើសំណើ និង បញ្ជីឈ្មោះបេក្ខជន ដោយភ្ជាប់មកជាមួយនូវកំណត់ហេតុប្រជុំវាយតម្លៃរបស់គណៈកម្មការពិនិត្យលក្ខណសម្បត្តិផង រួចហើយផ្ញើមកទីស្តីការគណៈរដ្ឋ-មន្ត្រី ដើម្បីពិនិត្យ និង ដាក់ជូនរាជរដ្ឋាភិបាលសំរេច ។

៣-វរជន មន្ត្រីរាជការ ដែលជ្រើសរើសជាបេក្ខជនត្រូវមានលក្ខណសម្បត្តិធំៗ ០៥ ចំណុចដូចខាងក្រោម ÷

ក- សីលធម៌រស់នៅស្អាតស្អំ មិនប្រព្រឹត្តអំពើពុករលួយ និងសកម្មភាពផ្ទុយពីច្បាប់រដ្ឋ ។

ខ- គំនិតផ្តួចផ្តើម និងមនសិការវិជ្ជាជីវៈខ្ពស់ សកម្មការងារ ឧស្សាហ៍ព្យាយាម ច្នៃប្រឌិត និងទទួលខុសត្រូវ ។

គ- ការដឹកនាំ និងគ្រប់គ្រងមានប្រសិទ្ធភាព ។

ឃ-ស្មារតីស្នេហាជាតិ គិតគូរដល់ផលប្រយោជន៍ជាតិ និងកិត្តិយសរបស់ក្រសួង ស្ថាប័ន។

ង- សាមគ្គីភាព និងទំនាក់ទំនងល្អជាមួយមហាជន ។

ផ្អែកតាមលក្ខណសម្បត្តិធំៗខាងលើ គណៈកម្មការពិនិត្យលក្ខណសម្បត្តិរបស់ក្រសួង ស្ថាប័ននិមួយៗ ត្រូវបង្កើតលក្ខណៈវិនិច្ឆ័យជាក់ស្តែង ស្របតាមវិស័យការងាររបស់ស្ថាប័នរៀងៗខ្លួន ។

៤- វរជន មន្ត្រីរាជការ កងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ ដែលបំរើការនៅតាមក្រសួងស្ថាប័ន ហើយបានពិនិត្យជ្រើសរើសជាបេក្ខជនដើម្បីស្នើផ្តល់គ្រឿងឥស្សរិយយស ចាំបាច់ត្រូវគិតទៅតាមទំហំស្នាដៃ និង ឆ្លាស់វេនគ្នារយៈពេល ០២ ឆ្នាំម្តង ។

៥- ចំនួនបេក្ខជនប្រចាំឆ្នាំនៃបណ្តាក្រសួងស្ថាប័ននិមួយៗ ដែលស្នើសុំគ្រឿងឥស្សរិយយស ត្រូវកំណត់មិនអោយលើសពី ១០ ភាគរយនៃចំនួនក្របខ័ណ្ឌសរុបរបស់ក្រសួងស្ថាប័នឡើយ ។ ក្នុងចំនួនសមាមាត្រ ១០ ភាគរយនេះ ត្រូវជ្រើសរើសពីក្នុងក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ ០២ ភាគរយ , មន្ត្រីក្របខ័ណ្ឌក្រមការ ០៣ ភាគរយ និងក្របខ័ណ្ឌលេខាធិការចំនួន ០៥ ភាគរយ ។

៦- ចំនួនបេក្ខជនដែលស្នើសុំគ្រឿងឥស្សរិយយសក្នុងលំដាប់ឋានានុក្រមខ្ពស់ ត្រូវអោយតិចជាងចំនួនបេក្ខ-ជនដែលស្នើសុំគ្រឿងឥស្សរិយយសក្នុងលំដាប់ឋានានុក្រមទាបជាង។ ក្នុងជំហានដំបូងត្រូវស្នើសុំគ្រឿងឥស្សរិយយសថ្នាក់ទាបសិន មុននឹងឈានទៅដល់ថ្នាក់ខ្ពស់ជាបន្តបន្ទាប់។ បេក្ខជនដែលជ្រើសរើសសំរាប់ស្នើសុំគ្រឿងឥស្សរិយយស

ក្នុងស្ថាប័ននិមួយៗ គឺ គិតតែក្នុងក្របខ័ណ្ឌមុខងារសាធារណៈតែប៉ុណ្ណោះ ។

ចំពោះមន្ត្រីថ្នាក់ដឹកនាំដែលជាសមាជិករាជរដ្ឋាភិបាល និង អនុរដ្ឋលេខាធិការ មិនត្រូវបញ្ចូលមកក្នុងបញ្ជីស្នើសុំគ្រឿងឥស្សរិយយសរបស់មន្ត្រីរាជការមុខងារសាធារណៈនេះទេ គណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស របស់រាជរដ្ឋាភិបាល និងរៀបចំជូនក្នុងបញ្ជីមួយដោយឡែក ។

៧- វរជន មន្ត្រីរាជការ ដែលបំពេញការងារក្នុងវិស័យនិមួយ ៗ អាចនឹងទទួលបានគ្រឿងឥស្សរិយយសផ្សេងខុសពីមុខជំនាញរបស់ខ្លួន ប្រសិនជាស្នាដៃ និង គុណបំណាច់នោះបំរើអោយវិស័យដទៃទៀត។ ក្នុងករណីនេះប្រធានស្ថាប័នជំនាញ ដែលទទួលបានផលប្រយោជន៍ពីស្នាដៃ និង គុណបំណាច់ខាងលើ ជាអ្នកធ្វើសំណើសុំមកទីស្តីការគណៈរដ្ឋមន្ត្រី ក្រោយពីពិភាក្សាឯកភាពជាមួយស្ថាប័នដែលគ្រប់គ្រងបេក្ខជនផ្ទាល់ ។

- ក្រសួងការពារជាតិ ជាអ្នកធ្វើសំណើសុំគ្រឿងឥស្សរិយយស ជូននាយទាហាន នាយទាហានរងពលទាហាន និងកងឯកភាពនៃកងយោធពលខេមរភូមិន្ទ ក្រោយពីបានទទួលសំណើតាមឋានានុក្រមពីអគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទរួចមក ។

- ក្រសួងស្ថាប័នជំនាញថ្នាក់កណ្តាល និង អាជ្ញាធរមូលដ្ឋានត្រូវមានការឯកភាពគ្នា មុននឹងស្នើសុំគ្រឿងឥស្សរិយយសជូនបេក្ខជន ដែលជាមន្ត្រីរាជការជំនាញនៅមូលដ្ឋាន ដោយក្រសួង ស្ថាប័ន ជាអ្នកធ្វើសំណើ ។

- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានភារកិច្ចពិនិត្យវាយតម្លៃការងាររបស់បណ្តាបុគ្គលិក អង្គទូត និងតំណាងប្រទេសជាមិត្ត ព្រមទាំងតំណាងអង្គការអន្តរជាតិនានា ដែលមកបំពេញភារកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា ហើយមានស្នាដៃ និង គុណបំណាច់ល្អប្រសើរ បំរើអោយផលប្រយោជន៍ប្រជារាស្ត្រខ្មែរដើម្បីស្នើសុំបំពាក់មេដាយសហមេត្រីតាមលំដាប់ថ្នាក់ មុនពេលបញ្ចប់អណត្តិនិមួយៗ ដោយគិតចាប់ពី ៣ ឆ្នាំឡើងទៅ ហើយក៏ត្រូវឯកភាពយល់ព្រមពីភាគីមិត្តជាមុនសិនដែរ មុននឹងស្នើមកទីស្តីការគណៈរដ្ឋមន្ត្រី ។

៨- ដើម្បីអោយស្របតាមព្រះរាជក្រឹត្យ និង អនុក្រឹត្យ លេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ ចំពោះបែបបទនៃការស្នើសុំមេដាយស្ថាបនាជាតិ ដែលបានអនុវត្តកន្លងមកត្រូវរក្សាការអនុវត្តដដែលដោយគ្រាន់ តែប្តូរឈ្មោះពី ÷

- *មេដាយស្ថាបនាជាតិថ្នាក់លេខ ១ ទៅជា មេដាយមាសស្ថាបនាជាតិ*

- *មេដាយស្ថាបនាជាតិថ្នាក់លេខ ២ ទៅជា មេដាយប្រាក់ស្ថាបនាជាតិ*

- *មេដាយស្ថាបនាជាតិថ្នាក់លេខ ៣ ទៅជា មេដាយសំរិទ្ធស្ថាបនាជាតិ*

មេដាយស្ថាបនាជាតិនេះ សំរាប់បំពាក់ជូនតែសប្បុរសជនដែលបានបរិច្ចាគធនធានរបស់ខ្លួនពិតប្រាកដតែប៉ុណ្ណោះ។ ចំពោះមន្ត្រីរាជការដែលពាក់ពន្ធ័ជាមួយសប្បុរសជន ឬ ជាអ្នកទាក់ទាញអំណោយពីសប្បុរសជន មិនត្រូវបានទទួលមេដាយខាងលើនេះឡើយ ។

៩- រាល់សំណើសុំគ្រឿងឥស្សរិយយសគ្រប់ប្រភេទ របស់ក្រសួងស្ថាប័ន លុះត្រាតែប្រមុខរាជរដ្ឋាភិបាល ចុះហត្ថលេខាលើអនុក្រឹត្យ ឬ ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្ថលេខាលើព្រះរាជក្រឹត្យ ទើបទីស្តីការគណៈរដ្ឋមន្ត្រី បើកគ្រឿងឥស្សរិយយសជូនបាន លើកលែងតែក្នុងករណីពិសេស បន្ទាន់ និងចាំបាច់ នាយករដ្ឋមន្ត្រីស្នើរៀបចំពិធីបំពាក់ជាមុន ទើបធ្វើបែបបទស្នើសុំជាក្រោយ ។

១០- គ្រឿងឥស្សរិយយសគ្រប់ប្រភេទ គ្រប់លំដាប់ថ្នាក់ដែលរាជរដ្ឋាភិបាល មន្ត្រីរាជការម្នាក់ៗបានទទួលត្រូវកត់ចូលក្នុងសំណុំឯកសារផ្ទាល់ខ្លួន ហើយត្រូវបានយកមកថ្លឹងថ្លែងជាគុណសម្បត្តិសំរាប់ការពិចារណា តម្លើងឋានន្តរសក្តិ ។

១១- គ្រប់ក្រសួងស្ថាប័នមានសមត្ថកិច្ច ត្រូវពិនិត្យវាយតម្លៃស្នាដៃឆ្នាំ ២០០០ ជូនមន្ត្រីរាជការក្រោមឱវាទ រួចបញ្ជូនសំណើមកទីស្តីការគណៈរដ្ឋមន្ត្រីអោយបានមុនថ្ងៃទី ១៥ ខែ មិនា ឆ្នាំ ២០០១ ដើម្បីបូកសរុប ពិនិត្យ និងសំរេច ជូននាឱកាសចូលឆ្នាំខ្មែរប្រពៃណីជាតិ ។ សំណើណាដែលមកក្រោយការកំណត់ខាងលើនេះ នឹងមិនត្រូវបានយកមកដោះស្រាយឡើយ ។

១២- បណ្តាក្រសួងស្ថាប័នមានសមត្ថកិច្ច ដែលមានគំរោងស្នើសុំគ្រឿងឥស្សរិយយស ត្រូវបញ្ជូនសំណើ និងបញ្ជីឈ្មោះបេក្ខជនអោយបានមកដល់ទីស្តីការគណៈរដ្ឋមន្ត្រី យ៉ាងយូរបំផុតត្រឹមថ្ងៃទី ៣០ ខែ កញ្ញា នៃឆ្នាំនិមួយៗ ដើម្បីអាចបូកសរុប ពិនិត្យ និងសំរេច ជូនគ្រឿងឥស្សរិយយស នាឱកាសដំណាច់ឆ្នាំ ។

សារាចរណែនាំលេខ ០៧ សរណន ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១៩៩៧ ត្រូវទុកជានិរាករណ៍ ។

រាជរដ្ឋាភិបាលសង្ឃឹមជឿជាក់ថា គ្រប់ក្រសួង ស្ថាប័ន គ្រប់ជាន់ថ្នាក់ នឹងចាត់ចែងអនុវត្ត តាមខ្លឹមសារនៃសារាចរណែនាំនេះ ប្រកបដោយស្មារតីយកចិត្តទុកដាក់ យុត្តិធម៌ ត្រឹមត្រូវ ស្មើភាព សំដៅរក្សាអោយបាននូវសុក្រឹតភាព និង តម្លៃ នៃគ្រឿងឥស្សរិយយសរបស់ជាតិ ។

<u>កន្លែងទទួល</u> :

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- គ្រប់ស្ថាប័ន- ក្រសួង- រដ្ឋលេខាធិការដ្ឋាន
- គ្រប់ខេត្ត- ក្រុង
- នាយកដ្ឋានសរុប
- រាជកិច្ច
- កាលប្បវត្តិ- ឯកសារ

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៦១ សសរ

ក្រសួងមុខងារសាធារណៈ
ផ្នែករដ្ឋបាល
លេខ ១២៧៣ អសខ
ថ្ងៃទី ០៥.០២.១៤

# សេចក្តីសម្រេច
# ស្តីពី
# ការតែងតាំងសមាសភាពគណៈកម្មការពិនិត្យលក្ខណសម្បត្តិ វរជនដែលត្រូវជូន គ្រឿងឥស្សរិយយស

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស /រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃ ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញ អនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការបង្កើត គណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស
-បានឃើញ អនុក្រឹត្យលេខ ៥៦៧ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៣ ស្តីពីការកែសម្រួល មាត្រា២ នៃអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការបង្កើត គណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស
-យោងតាមការចាំបាច់ នៃការងារ

## សម្រេច

**ប្រការ ១.-**

ត្រូវបានតែងតាំង សមាសភាព គណៈកម្មការពិនិត្យ លក្ខណសម្បត្តិវរជន ដែលត្រូវជូន គ្រឿងឥស្សរិយយស ដូចមានរាយនាមខាងក្រោម៖

| | | |
|---|---|---|
| ១-ឯកឧត្តម **សយ សុខា** | អគ្គលេខាធិការរាជរដ្ឋាភិបាល | ប្រធាន |
| ២-ឯកឧត្តម នាយឧត្តមសេនីយ៍ **យូ ស៊ុនឡុង** | រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ | អនុប្រធាន |
| ៣-ឯកឧត្តមនាយឧត្តមសេនីយ៍ **នាង ផាត** | រដ្ឋលេខាធិការ ក្រសួងការពារជាតិ | សមាជិក |
| ៤-ឯកឧត្តម **លេង ទី** | អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | សមាជិក |
| ៥-ឯកឧត្តម **ធឿន ម៉ៅ** | អនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៦-លោក **មាន់ សារូ** | ប្រធាននាយកដ្ឋានឥស្សរិយយស ទីស្តីការគណៈរដ្ឋមន្ត្រី | លេខាធិការ |

សមាសភាពគណៈកម្មការខាងលើ ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធានគណៈកម្មការ។

**ប្រការ ២.-**

បទប្បញ្ញត្តិ ទាំងឡាយណា ដែលផ្ទុយនឹង សេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២១ ខែ មិនា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ៣
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ:** ០៧ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ
&&&&&
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស /រកត /១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

## ស ំ រ េ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីចំនួន ១៩ រូប នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ដែលមានស្នាដៃល្អក្នុងការបំពេញការងារ ឆ្នាំ ២០០២ ដូចមានរាយនាមខាងក្រោម ÷

**ក_មេដាយប្រាក់ការងារ**

| | | | |
|---|---|---|---|
| ១-លោក | **សឿ** | **ប៊ុនហ៊ះ** | អធិការ |
| ២-លោក | **ជាក់** | **ម៉េងហ៊ាង** | អនុប្រធាននាយកដ្ឋាន |
| ៣-លោក | **អ៊ុយ** | **តារក្ស** | នាយខុទ្ទកាល័យ |
| ៤-លោក | **ខៀវ** | **ប៊ុន្ណា** | អនុប្រធានការិយាល័យ |
| ៥-លោក | **សៅ** | **ឆាយ** | ប្រធានការិយាល័យ |
| ៦-លោក | **ហ៊ីង** | **គឹមស៊ាង** | ប្រធានការិយាល័យ |
| ៧-លោកស្រី | **ឌូ** | **សុជាតិ** | អនុប្រធានការិយាល័យ |

**ខ_មេដាយសំរឹទ្ធការងារ**

| | | | |
|---|---|---|---|
| ១-លោក | ស | សាម៉ុឌី | ប្រធានការិយាល័យ |
| ២-លោក | មាស | សុវ៉ាធី | អនុប្រធានការិយាល័យ |

៣-លោក **ត្រាក់ តា** អនុប្រធានការិយាល័យ

៤-អ្នកស្រី **អ៊ឹម សុវណ្ណារី** មន្ត្រី

៥-លោក **អៀង មុន្នី** អនុប្រធានការិយាល័យ

៦-អ្នកស្រី **សួស វ៉ាន់ស៊ី** មន្ត្រី

៧-លោក **ម៉ូ ផល្លា** អនុប្រធានការិយាល័យ

៨-លោក **គឹម ណារី** អនុប្រធានការិយាល័យ

៩-លោក **អ៊ឹច ហោង** អនុប្រធានការិយាល័យ

១០-លោក **ពត ប៊ុនឈឿន** មន្ត្រី

១១-លោក **ឌិត្យ សីហារ៉ាវុធ** មន្ត្រី

១២-លោក **ខ្វិ សំអែល** មន្ត្រី

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និង មាត្រា២
-រាជកិច្ច
-ឯកសារ- កាលប្បវត្តិ

# ប្រកាសនិយប័ត្រ គ្រឿងឥស្សរិយយស ការងារ

## រាជរដ្ឋាភិបាល កម្ពុជា

ជូនចំពោះលោក **ស សាម៉ីឌី** ប្រធានការិយាល័យ

**ដែលមានស្នាដៃល្អ ក្នុងការបំពេញការងារ ឆ្នាំ ២០០២**

ដើម្បីជាសក្ខីភាពនៃការដឹងគុណរបស់រាជរដ្ឋាភិបាល និងបណ្តារាស្ត្រខ្មែរនូវឥស្សរិយយស **ការងារថ្នាក់** មេដាយ **សំរិទ្ធ**

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០៣

លេខ : ០២ អនក្រ.តត

ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០៣

ចុះបញ្ជីលេខ : ៧៤៩

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:.........៧២.....អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ចំនួន២០រូប នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចកន្លងមក ដូចមានរាយនាមខាងក្រោម :-

**ក_មេដាយមាសការងារ :**

| | | | |
|---|---|---|---|
| ១-លោក | **អ៊ុច** | **សុផុន** | អធិការ |
| ២-លោក | **តេង** | **គឹមជាក** | អនុប្រធាននាយកដ្ឋាន |
| ៣-លោក | **អ៊ុន** | **ព្រុំ** | អនុប្រធាននាយកដ្ឋាន |
| ៤-លោក | **ឌី** | **សារិន** | អនុប្រធាននាយកដ្ឋាន |
| ៥-លោក | **ថៅ** | **មូលប៊ុនថាត** | អធិការ |
| ៦-លោកស្រី | **សៅ** | **សុគន្ធារី** | អនុប្រធាននាយកដ្ឋាន |
| ៧-លោក | **យ៉ោ** | **សុភាព** | អនុប្រធាននាយកដ្ឋាន |
| ៨-លោក | **ស** | **សាម៊ីឌី** | ប្រធាននាយកដ្ឋាន |

**ខ_មេដាយប្រាក់ការងារ :**

| | | | |
|---|---|---|---|
| ១-លោក | **អុល** | **រី** | អនុប្រធាននាយកដ្ឋាន |
| ២-លោក | **មាស** | **ពេជ្រ** | អនុប្រធាននាយកដ្ឋាន |
| ៣-លោកស្រី | **ឱម** | **នរេន្ទ្រ** | ប្រធានការិយាល័យ |

៤-លោក **ថាវ ចាន់ដេ** ប្រធានការិយាល័យ

៥-លោកស្រី **ហ៊ល សាធាលីន** អនុប្រធានការិយាល័យ

**គ_មេដាយសីវត្ថភារខារ :**

១-លោក **ហែម មគ្គផល** ប្រធានការិយាល័យ

២-លោក **សាវ៉េត ម៉ាឌី** ប្រធានការិយាល័យ

៣-លោក **កែវ សាក់** អនុប្រធានការិយាល័យ

៤-លោក **ឆេន ដួចគិរក្ស** អនុប្រធានការិយាល័យ

៥-លោក **រស់ សុគំគ្គ** អនុប្រធានការិយាល័យ

៦-លោក **ចំន្ទ សុគន្ធ** អនុប្រធានការិយាល័យ

៧-លោក **វេទ លាភ** អនុប្រធានការិយាល័យ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ប្រកាសនិយប័ត្រ គ្រឿងឥស្សរិយយស ការងារ

## រាជរដ្ឋាភិបាល កម្ពុជា

ជូនចំពោះលោក **ស សាម៉ីឌី**

ប្រធាន នាយកដ្ឋាន នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

**ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ច ជូនរដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ**

ដើម្បីជាសក្ខីភាពនៃការដឹងគុណរបស់រាជរដ្ឋាភិបាល និង បណ្ដារាស្ត្រខ្មែរនូវ ឥស្សរិយយស ការងារថ្នាក់ មេដាយ មាស

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

លេខ ៨២ អនក្រ.តត

ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៦

បញ្ជីលេខ : ២៨០

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៤៤៨ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសុវត្ថារា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
